ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ.៤២៥.សរ.ណ.../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី០៣. ខែមិថុនា ឆ្នាំ២០១៥

**ជម្រាបជូន**

**លោកស្រី ជេត ចរិយា នាយិកាប្រតិបត្តិ នៃអង្គការស្ការកម្ពុជា**

**<u>កម្មវត្ថុ</u>៖** អំពីសំណើសុំគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមរបស់អង្គការស្ការកម្ពុជា នៅក្នុងស្រុកគោលដៅចំនួន៦ ឃុំចំនួន១១ នៃខេត្តស្វាយរៀង ខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។

**<u>យោង</u>៖** -លិខិតលេខ៣៣/២០១៥ស្ការកម្ពុជា ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ស្នើសុំគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម របស់អង្គការស្ការកម្ពុជា។
-ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកស្រីនាយិកាប្រតិបត្តិជ្រាបថា៖ លេខាធិការដ្ឋាន គ.ជ.អ.ប សូមគាំទ្រ និងសហការជាមួយអង្គការស្ការកម្ពុជា លើការអនុវត្តផែនការសកម្មភាពផ្នែកតម្រូវការ ក្នុងផែនការយុទ្ធសាស្ត្រស្តីពី ការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលផ្តោតសំខាន់លើសេវាមូលដ្ឋានទាំងបីរួមមាន៖ ការផ្តល់សេវារបស់រដ្ឋបាលឃុំ សេវាមណ្ឌលសុខភាព និងសាលាបឋមសិក្សា នៅក្នុងឃុំចំនួន១១ ស្រុកគោលដៅចំនួន៦ នៃខេត្តចំនួន៣ គឺខេត្តស្វាយរៀង ខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ សម្រាប់ឆ្នាំ២០១៥នេះ ដូចមានលម្អិតក្នុងតារាង ភ្ជាប់ជូនមកជាមួយ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមលោកស្រីនាយិកាប្រតិបត្តិ មេត្តាចាត់ចែងអនុវត្តតាមនីតិវិធី ប្រើប្រាស់ឧបករណ៍គណនេយ្យភាពសង្គម ដែលលេខាធិការដ្ឋាន គ.ជ.អ.ប បានដាក់ឲ្យអនុវត្ត និងត្រូវសហការជាមួយរដ្ឋបាលខេត្ត ស្រុក ឃុំ និងអ្នកពាក់ព័ន្ធ នៅតាមតំបន់គោលដៅដែលបានកំណត់ ឲ្យទទួលបាន លទ្ធផលល្អប្រសើរ។

សូមលោកស្រីនាយិកាប្រតិបត្តិ ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**
អនុប្រធាន

ជាន់ ចំរើន

**<u>ចម្លងជូន៖</u>**
- រដ្ឋបាលខេត្តស្វាយរៀង ខេត្តពោធិ៍សាត់ និង ខេត្តបន្ទាយមានជ័យ
- រដ្ឋបាលស្រុក ឃុំ គោលដៅ
  "ដើម្បីសហការអនុវត្ត"
- ឯកសារកាលប្បវត្តិ

# តំបន់គោលដៅ

## ក្នុងការអនុវត្ត ផែនការយុទ្ធសាស្ត្រស្តីពីការទារគណនេយ្យភាពសង្គម ឆ្នាំ ២០១៥

## របស់អង្គការស្តារកម្ពុជា

| ខេត្ត | ស្រុករដ្ឋបាល | ឃុំ | មណ្ឌលសុខភាព | សាលារៀនបឋមសិក្សា |
|---|---|---|---|---|
| ពោធិ៍សាត់ | កណ្តៀង | ស្រែស្តុក | មណ្ឌលសុខភាពស្រែស្តុក | ក្តីឧត្តម |
| | | | | ទន្លេអុំ |
| | | | | ព្រះធាតុ |
| | | | | ស្តៅជ្រុំ |
| | | | | សែនជ័យ |
| | | | | ពោធិ៍ពី |
| | | | | ចំរេះ |
| | ក្រគរ | អន្សាចំបក់ | មណ្ឌលសុខភាពអន្សារចំបក់ | ឯសុធា |
| | | | | វិហារល្បួង |
| | | | | កោះរំដួល |
| | | | | កំពង់ថ្កោល |
| | | អន្លង់ត្នោត | មន្ទីរពេទ្យបង្អែកស្រុកក្រគរ | អន្លង់ត្នោត |
| | | | | ទួលខ្ពស់ |
| | | | | វត្តបន្ទាយក្រង |
| | | | | វត្តចាស់ |
| | | | | ខ្លាក្រពើ |
| | | | | ជ្រលង |
| | | ក្បាលត្រាច | មន្ទីរពេទ្យបង្អែកស្រុកក្រគរ | ក្រឡាញ់ |
| | | | | ត្រពាំងរំដេញ |
| | | | | ត្រពាំងស្នាច់ |
| | | | | ក្បាលត្រាច |
| | | | | ត្រស់ |
| | | | | ម្រាក់ទាប |

| | | | | |
|---|---|---|---|---|
| ស្វាយរៀង | រមាសហែក | ត្រស់ | មណ្ឌលសុខភាពឃុំអំពិល | ត្រពាំងបន្ទាយ |
| | | | | តាសួស |
| | | គគីរ | មណ្ឌលសុខភាពឃុំអំពិល | គគីរ |
| | | អំពិល | មណ្ឌលសុខភាពឃុំអំពិល | អំពិល |
| | | | | រមាសហែក |
| | | | | ឧបសម្ព័ន្ធត្រពាំងពិការ |
| | | ក្រសាំង | មណ្ឌលសុខភាពឃុំក្រសាំង | ក្រសាំង |
| | | | | ទួលតារាម |
| | ចន្ទ្រា | ចន្ទ្រា | មណ្ឌលសុខភាពឃុំទួលស្ដី | ចន្ទ្រា |
| បន្ទាយមានជ័យ | អូរជ្រៅ | អូរបីជាន់ | មណ្ឌលសុខភាពថ្មល់បត់ | យាងអភិវឌ្ឍន៍ |
| | | | | យាងដង្កុំ |
| | | | | ព្រាវ |
| | | | | ស្ទួលទ្រេត ៩៨ |
| | | | មណ្ឌលសុខភាពសិលាខ្មែរ | ស្ទួលទ្រេត ៩៩ |
| | | | | ជោគជ័យ |
| | | | | ទំនប់ដាច់ |
| | | | | សិលាខ្មែរ |
| | | | | ព្រៃចាន់ |
| | ម៉ាឡៃ | តាគង់ | មណ្ឌលសុខភាពបល្ល័ង្គ | តាគង់ |
| | | | | បល្ល័ង្គ |
| | | | | ថែងម៉ែង |
| | | | | ប៉ោយអង្គរ |
| | | | | បុស្សធំ |
| | | | | ដំណាក់ថ្មី |
| | | | | ខ្លាយ |
| | | | | ស្រះភ្លោះ |
| | | | | ប្រាសាទវ៉ាង |
| | | | | បឹងក្រោក |
| | | | | អូរស្វាយ |
| សរុប | ០៦ ស្រុក | ១១ ឃុំ | ០៩ មណ្ឌលសុខភាព | ៥២ សាលា |